សម្លេងខ្មែរនៅបរទេស

# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ អំពីសទ្ធាឬជំនឿក្នុងព្រះពុទ្ធសាសនា

web site: hoksavann.org

ថ្ងៃទី២០ សីហា ២០០៥

ពាក្យថា <សទ្ធា> ជាភាសាបាលី មកពី សំ បុព្វបទ និងធា ធាតុ ។ ធាប្រែថា ទ្រង់ទ្រទ្រង់ សំប្រែថាព្រម រួមពាក្យទាំងពីរបទ សទ្ធាតាមស័ព្ទដើមប្រែថាទ្រទ្រង់ព្រម ។ បានសេចក្តីថា ទ្រទ្រង់នូវសេចក្តីពិត ដែលគេបានពិចារណាឬពិសោធន៍ឃើញ ឧទាហរណ៍បានដល់គណិតវិទ្យា ពីរបូកនិងពីរត្រូវជាបួន ឃើញហេតុផលពិតនេះ ក៏ទ្រទ្រង់ឬជឿពាក្យនោះទៅ ។ តាមគីមីវិទ្យា ២អ៊ីដ្រូសែនបូកនិងអុកស៊ីសែន១ កើតបានជាទឹក បើអនុវត្តទៅឃើញការពិតដូច្នេះមែន ក៏ទ្រទ្រង់ឬជឿពាក្យនោះទៅ ។ ដូចជឿការពិតថា លូកភ្លើងក្តៅ ដាំពូជបែបណារមែងបានផលបែបនោះ គឺដាំពោតបានផលជាពោត ដាំស្រូវបានផលជាស្រូវជាដើម ។ សទ្ធាឬជំនឿក្នុងព្រះពុទ្ធសាសនាមានបញ្ញាការពិចារណានៅជាមួយ បើឃើញការពិតបែបណា ក៏ទ្រទ្រង់ឬជឿបែបនោះ ដូចពាក្យថា ធ្វើបុណ្យបានបុណ្យ ធ្វើបាបបានបាប ។ ជឿព្រះពុទ្ធសាសនា គឺជឿការពិតដែលព្រះពុទ្ធបានសំដែង ដូចជឿការត្រាស់ដឹងរបស់ព្រះអង្គក្នុងអរិយសច្ច៤ មានទុក្ខសច្ចជាដើម ជឿព្រះធម៌គឺមគ្គប្រកបដោយអង្គ៨ជាធម៌ ធ្វើឲ្យអ្នកប្រតិបត្តិតាមដល់នូវទីរំលត់ទុក្ខពិតមែន ជឿព្រះសង្ឃជាអ្នកទ្រទ្រង់នូវគុណ មានសីលគុណជាដើមពិតមែន ។ ជឿព្រះពុទ្ធសាសនាគឺហេតុជឿផល ឬជឿកម្មផលជាយថាវត្ថុ គឺធម្មជាតិរបស់វាយ៉ាងណា វាប្រព្រឹត្តយ៉ាងនោះជាស្វ័យប្រវត្តិដោយខ្លួនឯង ពុំមែនកើតឡើងពីព្រះជាម្ចាស់អង្គណាឡើយ ។ ព្រះសម្ពុទ្ធប្រៀនប្រដៅពុទ្ធបរិស័ទកុំឲ្យជឿពាក្យដែលនិយាយតៗគ្នា តែត្រូវជឿការពិត បន្ទាប់ពីបានពិចារណានិងធ្វើការពិសោធន៍រួចហើយ ។ ជំនឿខុសនាំឲ្យធ្វើខុស ជំនឿត្រូវនាំឲ្យធ្វើត្រូវ ។ សទ្ធានេះមាននិយាយក្នុងពលៈ៥ ហៅថា សទ្ធាពលៈ ប្រែថាធម៌ជាកម្លាំងនៃសទ្ធា នៅក្នុងឥន្ទ្រីយ៍៥ ហៅថា សទ្ធិន្ទ្រីយ៍ ប្រែថាធម៌ជាធំគឺសទ្ធា ។ ពុទ្ធបរិស័ទខ្មែរបានប្រតិបត្តិតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ដោយមានជំនឿយ៉ាងមុតមាំថា ព្រះធម៌ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធនោះអាចនាំឲ្យគេបានសុខចំរើនរហូតដល់ទីរំលត់ទុក្ខ ពោលគឺព្រះនិព្វាន ។ ព្រះពុទ្ធសាសនាជាសាសនាមិនបង្ខំមនុស្សឲ្យជឿ នេះជាគោលការណ៍ដ៏សំខាន់របស់ព្រះពុទ្ធដែលគោរពសិទ្ធិអ្នកដទៃ ដោយព្រះពុទ្ធដីកាថា អ្នកទាំងឡាយមានសិទ្ធិដ៏ពេញលេញ ក្នុងការពិចារណានូវធម៌តថាគត មុននឹងសំរេចចិត្តជឿ ។ ផ្ទុយតៅវិញ មានសាសនាខ្លះបានបង្ខំឲ្យមនុស្សជឿសាសនាខ្លួន ដោយមធ្យោបាយផ្សេងៗ មានផ្តល់ជាវត្ថុផ្សេងៗជាផ្លាក់ទាក់ទឹកចិត្ត ,៚